ក

# មាតិកា

## I~ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២៦-៥-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៥០៧/២១០ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី **លី គីក្វាង** ( LEE KYE KWANG ) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ៤២៨២

០៣-៦-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៦០៧/២១៤ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ លោកតាមហាឧបាសក **ហ៊ុន នាង** និង លោកយាយមហាឧបាសិកា **ឌី ស៊ាងលី** ៤២៨៣

០៤-៦-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៦០៧/២១៦ ស្តីពីការតម្លើងថ្នាក់មន្ត្រីរាជការឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងព្រះបរមរាជវាំង ៤២៨៤

០៦-៦-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៦០៧/២១៧ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជូនលោកវរសេនីយ៍ឯក **នៅ លក្ខិណា** នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៤២៨៥

០៦-៦-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៦០៧/២១៩ ស្តីពីការតម្លើងឋានៈឯកឧត្តម **ម៉ែន ម៉ុនណយ៉ា** នាយករងអង្គភាពគ្រប់គ្រងគម្រោង នៃក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានឋានៈស្មើ អគ្គនាយក ៤២៨៦


## II~ក្រុមប្រឹក្សាធម្មនុញ្ញ

### សេចក្តីសំរេច


០៥-៦-២០០៧ -សេចក្តីសំរេចលេខ ១៤១.២០០៧ កបធ.សសរ ស្តីពីរបបប្រាក់សោធននិវត្តន៍ នៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ៤២៨៧


## III~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


០៦-៦-២០០៧ -អនុក្រឹត្យ លេខ ៥៦ អនក្រ.បក ស្តីពីការបង្កើតនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងសាធារណការ និងដឹកជញ្ជូន ៤២៩០

| | | |
|---|---|---|
| ០៧-៦-២០០៧ | -អនុក្រឹត្យលេខ ៥៧ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី | ៤២៩៣ |
| ០៥-៦-២០០៧ | -អនុក្រឹត្យលេខ ៤៤៣ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ | ៤៣០២ |
| ០៥-៦-២០០៧ | -អនុក្រឹត្យលេខ ៤៤៤ អនក្រ.តត ស្តីពីការកែសំរួលមុខតំណែង នាយនគរបាលជាតិ | ៤៣០៣ |
| ០៥-៦-២០០៧ | -អនុក្រឹត្យលេខ ៤៤៥ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ | ៤៣០៤ |
| ០៦-៦-២០០៧ | -អនុក្រឹត្យលេខ ៤៤៦ អនក្រ.តត ស្តីពីការតែងតាំងសមាសភាពអគ្គលេខាធិការរងបន្ថែម របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | ៤៣០៥ |
| ០៦-៦-២០០៧ | -អនុក្រឹត្យលេខ ៤៤៧ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី | ៤៣០៦ |
| ០៦-៦-២០០៧ | -អនុក្រឹត្យលេខ ៤៤៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៤៣០៧ |
| ០៦-៦-២០០៧ | -អនុក្រឹត្យលេខ ៤៤៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៤៣០៨ |
| ០៦-៦-២០០៧ | -អនុក្រឹត្យលេខ ៤៥០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៤៣០៩ |
| ០៦-៦-២០០៧ | -អនុក្រឹត្យលេខ ៤៥១ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ | ៤៣១០ |
| ០៦-៦-២០០៧ | -អនុក្រឹត្យលេខ ៤៥២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៤៣១១ |
| ១១-៦-២០០៧ | -អនុក្រឹត្យលេខ៤៥៣ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពការិយាល័យរបស់ក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិកម្ពុជាសំរាប់អាណត្តិ ២ ឆ្នាំ លើកទី ៣ | ៤៣១២ |
| ១១-៦-២០០៧ | -អនុក្រឹត្យលេខ៤៥៤ អនក្រ.តត ស្តីពីការកែសំរួលសមាសភាពក្រុមការងារគ្រប់គ្រងសម្បទាន នៃក្រុមការងារសំរាប់អនុវត្តគម្រោងស្តារ ជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកកម្ពុជា ដោយគាំរោងថវិកាកម្ចីធនាគារអភិវឌ្ឍន៍-អាស៊ី | ៤៣១៤ |
| ១១-៦-២០០៧ | -អនុក្រឹត្យលេខ ៤៥៥ អនក្រ.តត ស្តីពីការកំណត់ក្របខ័ណ្ឌមន្ត្រីក្រមការ និងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យមតាមលក្ខន្តិកៈដោយឡែក | ៤៣១៦ |


## ២_សេចក្តីសំរេច


* សេចក្តីសំរេចលេខ ២៧ សសរ. ( មិនទាន់បានទទួលឯកសារ )

| | | |
|---|---|---|
| ០៧-៦-២០០៧ | - សេចក្តីសំរេចលេខ ២៨ សសរ. ស្តីពីការប្រកាសកាលបរិច្ឆេទ នៃការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ សំរាប់នីតិកាលទី ៤ នៃរដ្ឋសភា | ៤៣៣៣ |

# IV~ការងារបណ្តាក្រសួង

## ១~ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

### សេចក្តីណែនាំ


០៥-៦-២០០៧ -សេចក្តីណែនាំលេខ ២៩៤៣ កសក អនុវត្តសារាចររាជរដ្ឋាភិបាល លេខ ០២ សរ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់ ក្រោមដែនសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ ៤៣៣៤


## ២~ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


៣០-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤៩០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌីណាស្ត្រា ខូ អិលធីឌី** ៤៣៣៨

៣០-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤៩៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេ អិម ស៊ី** ៤៣៤០

៣០-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤៩៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដែលតា ខនសាល់ធីង & ត្រេឌីង** ៤៣៤២

៣១-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤៩៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជី & ធី អរ អ៊ិនធើណេសិនណល (ខេមបូឌា)** ៤៣៤៤

៣១-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤៩៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហុង អិន អ៊ិនធើណេសិនណល** ៤៣៤៦

៣១-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៥០០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមបូឌាន មេគង អ៊ិនដាសស្ទ្រី** ៤៣៤៨

៣១-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៥០១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឡាក់ឃី ហ្វាម៉ា** ៤៣៥០

០១-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៥០៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមរា ហ្វ៊ូដ អ៊ិនដាសស្ទ្រី** ៤៣៥២

០១-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៥០៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អប្សរា ស៊ីហ្វូដ** ៤៣៥៤

០១-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៥០៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **រ៉ូយ៉ាល់ ខនគ្រីត ប្រូដាក់** ៤៣៥៦

០១-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៥០៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឧន្លេ ស្ទ័ហ្វើរ ខេន** ៤៣៥៨

០១-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៥១០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ពិភព អេស៊ា ទ្រេឌីង** ៤៣៦០

០១-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៥១១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អន្តរ ស្ទ័ហ្វើរ** ៤៣៦២

០១-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៥១២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **(ខេមបូឌា) ខេន អេន ស្ទ័ហ្វើរ ថែលលី** ៤៣៦៤

០១-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៥១៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប៊ីល ឌីវេឡុបមេន** ៤៣៦៦

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

**គឹម_ស៊ីថន**

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៧/២១០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី លី គីក្វាង (LEE KYE KWANG) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៦៨ នៅក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

លេខៈ៥៨១ ច.ល
ជូនចំពោះចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ ចិនកេន

៣៧.០៧០៥.២២២

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៧*

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៧/២១៤

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា )

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

ចំពោះ

១- លោកតាមហាឧបាសក ហ៊ុន នាង
២- លោកយាយមហាឧបាសិកា ប៊ុន ស៊ាងលី

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៧
ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

៣.ល.០៧០៦.២២៦

លេខ:២៣០ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០០៧
អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៧/២១៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងថ្នាក់មន្ត្រីរាជការឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងព្រះបរមរាជវាំង មានដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១ | ឯកឧត្តម ឈា ហន | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣ | ទៅថ្នាក់លេខ ២ |
| ២ | ឯកឧត្តម អ៊ុំ ឯម | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣ | ទៅថ្នាក់លេខ ២ |
| ៣ | ឯកឧត្តម ស្រី ណារី | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥ | ទៅថ្នាក់លេខ ៤ |
| ៤ | ឯកឧត្តម អ៊ុំ វិជ្ជាវ៉ាវុធ | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥ | ទៅថ្នាក់លេខ ៤ |

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៧
**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហាត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

ចរ/ល.០៧០៦-២២៩
លេខ: ២២៨៦.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចាន់ថុល

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៧/២១៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជូនលោកវរសេនីយ៍ឯក នៅ ឈឿនសា អត្តលេខ ០៤៣២ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៧*

*ក្នុងព្រះបរមនាម និង តាមព្រះរាជគ្រាស់បង្គាប់*

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣៣. ០៧០៦. ២២៩

លេខ: ២៦៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ស៊ុន ចិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៧/២១៩

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្នត្រ័យ ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

### ត្រាស់បង្គាប់

**មាត្រា១:** ត្រូវបានតម្លើងឋានៈឯកឧត្តម ប៉ែន ប៊ុនឈា នាយករងអង្គភាពគ្រប់គ្រងគម្រោង នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានឋានៈស្មើ អគ្គនាយក ។

**មាត្រា២:** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៧
គ្រងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

៣រល.០៧០៦.២៣១
លេខ:២២៤៦.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

យុន មីនកេន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ ១៤/២០០៧ កបធ.សសរ

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០៧

# សេចក្តីសម្រេច

## ស្តីពី

## របបប្រាក់សោធននិវត្តន៍ នៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ

**ក្រុមប្រឹក្សាធម្មនុញ្ញ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៦/០២៥ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ
- យោងសម័យប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៧

## សម្រេច

## ជំពូកទី១

## ប្រាក់សោធននិវត្តន៍

**ប្រការ១ :** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញទទួលប្រាក់សោធននិវត្តន៍បាន លុះត្រាតែបានបំពេញល័ក្ខខ័ណ្ឌដូចខាងក្រោម :

- ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ គិតចាប់ពីឆ្នាំ ១៩៩៨ មក
- មានអាយុចាប់ពី ៦០ឆ្នាំឡើង
- មិនបានទទួលប្រាក់សោធននិវត្តន៍ពីស្ថាប័នណាមួយរបស់រដ្ឋទេ ។
- ត្រូវធ្វើពាក្យសុំចូលនិវត្តន៍

**ប្រការ២ :** ប្រាក់សោធននិវត្តន៍ប្រចាំខែរបស់និវត្តជនម្នាក់ៗត្រូវផ្អែកលើប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់យ៉ាងនៃឆ្នាំដែលសមាជិកក្រុមប្រឹក្សាធម្មនុញ្ញបានទទួលខ្ពស់បំផុត ដោយគិតទាំងឋានៈមុខងារផងដែរ កំណត់ស្មើមួយរយភាគរយ ។

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣, E-mail: sgcc@camnet.com.kh

**ប្រការ៣** : ប្រាក់សោធននិវត្តន៍ប្រចាំខែត្រូវកំណត់ដោយផ្អែកលើរយៈពេលបំពេញការងារដូចតទៅ :

- ពី ១ឆ្នាំ ដល់ ៣ឆ្នាំ ទទួលបានសន្ទស្សន៍ 0.៥ %
- លើសពី ៣ឆ្នាំ ដល់ក្រោម ៦ឆ្នាំ ទទួលបានសន្ទស្សន៍ ១ %
- ពី ៦ឆ្នាំ ដល់ក្រោម ១១ឆ្នាំ ទទួលបានសន្ទស្សន៍ ២ %
- ពី ១១ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ ទទួលបានសន្ទស្សន៍ ៣ %
- ពី ១៦ឆ្នាំ ឡើងទៅ ទទួលបានសន្ទស្សន៍ ៤ %

ការគណនាប្រាក់សោធននិវត្តន៍ប្រចាំខែរបស់និវត្តជនត្រូវអនុវត្តតាមរូបមន្តដូចខាងក្រោម :

| ប្រាក់សោធននិវត្តន៍ប្រចាំខែ = ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់យ៉ាងនៃឆ្នាំខ្ពស់បំផុត × សន្ទស្សន៍ |
|---|

ប្រាក់សោធននិវត្តន៍ប្រចាំខែអាចប្រែប្រួលបានទៅតាមប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភគ្រប់យ៉ាងនៃថវិកាប្រចាំឆ្នាំខ្ពស់បំផុត ដោយមិនគិតជានិវត្តជនមុន ឬ និវត្តជនក្រោយឡើយ ។

**ប្រការ៤** : និវត្តជនជាអតីតសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ នៅពេលជាប់ឆ្នោតជាតំណាងរាស្ត្រ ឬ សមាជិកព្រឹទ្ធសភា មិនត្រូវបានបើកផ្តល់ប្រាក់សោធននិវត្តន៍ទេ ។ សាមីជនត្រូវបើកប្រាក់បំណាច់ជាតំណាងរាស្ត្រ ឬ សមាជិកព្រឹទ្ធសភាជាធម្មតា ហើយនៅពេលចប់អាណត្តិទើបសាមីជនបើកប្រាក់សោធននិវត្តន៍វិញសាជាថ្មី ដោយកែសម្រួលសន្ទស្សន៍ទៅតាមអតីតភាព ។

**ប្រការ៥** : របៀបគិតអតីតភាពការងារ របស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ គឺមានដូចតទៅ :

- ត្រូវរាប់បញ្ចូលអតីតភាពការងារជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ នូវអតីតភាពការងារដែលនិវត្តជនបានធ្វើជាតំណាងរាស្ត្រ ឬ/និង សមាជិកព្រឹទ្ធសភា (ក្នុងករណីមានច្បាប់ស្តីពីសោធននិវត្តន៍ នៃសមាជិកព្រឹទ្ធសភា)
- មានអតីតភាព ចាប់ពី ១៦ថ្ងៃឡើងទៅ ត្រូវគិតស្មើ ១ខែ
- មានអតីតភាព ចាប់ពី ៦ខែឡើងទៅ ត្រូវគិតស្មើ ១ឆ្នាំ

## ជំពូកទី២

## ភារកិច្ច និងសមត្ថកិច្ចគ្រប់គ្រងប្រាក់សោធននិវត្តន៍

**ប្រការ៦** : ជារៀងរាល់ឆ្នាំ ក្រោមការណែនាំរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញត្រូវរៀបចំគម្រោងផែនការស្ថិតិ និងថវិកាប្រាក់សោធននិវត្តន៍ និងប្រាក់ធានារ៉ាប់រងសង្គមសម្រាប់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលគ្រប់ល័ក្ខខ័ណ្ឌចូលនិវត្តន៍ និងទទួលមរណភាព ដើម្បីដាក់ឆ្លងក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យសម្រេច បញ្ចូលក្នុងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

**ប្រការ៧** : ការបើកប្រាក់សោធននិវត្តន៍ និងប្រាក់ធានារ៉ាប់រងសង្គមរបស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ធ្វើឡើងនៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ។

## ជំពូកទី៣

## អវសានប្បញ្ញត្តិ

**ប្រការ៨** : សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីឆ្នាំ ២០០៨ តទៅ ។

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ប៊ិន ឈិន

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ៥៦ អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងសាធារណការ និងដឹកជញ្ជូន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើតនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា២.-**

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិមានតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

១- សម្របសម្រួល និងធ្វើទំនាក់ទំនងការងារសហប្រតិបត្តិការអន្តរជាតិ ជាមួយក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ លើវិស័យសាធារណការ និងដឹកជញ្ជូន ។

២- ពង្រឹងកិច្ចសហប្រតិបត្តិការ និងសម្របសម្រួលទំនាក់ទំនងជាមួយអង្គការអន្តរជាតិ អង្គការសង្គមស៊ីវិល របស់បណ្តាប្រទេសនានា ដែលផ្តល់ការគាំទ្រលើវិស័យសាធារណការ និងដឹកជញ្ជូន តាមគោលការណ៍ របស់រាជរដ្ឋាភិបាល ។

៣- រៀបចំសំណុំឯកសារផ្សេងៗ ដែលពាក់ព័ន្ធនឹងកិច្ចការអន្តរជាតិជូនថ្នាក់ដឹកនាំក្រសួងសម្រាប់ចរចា និង ចុះហត្ថលេខាលើកំណត់ហេតុ អនុស្សរណៈ ពិធីសារ និងកិច្ចព្រមព្រៀងផ្សេងៗ ។

៤- សហការសម្របសម្រួលរាល់សកម្មភាពគ្រប់អង្គភាព ដែលដំណើរការក្រោមឥណទានរបស់ជំនួយ ទ្វេភាគី ពហុភាគី ជាមួយរាជរដ្ឋាភិបាល ឬជាមួយក្រសួង ស្ថាប័ននានា ។

៥- សម្របសម្រួល និងគ្រប់គ្រងទិន្នន័យព័ត៌មានជំនួយ និងកម្ចីបរទេស ដែលពាក់ព័ន្ធជាមួយវិស័យ សាធារណការ និងដឹកជញ្ជូន ។

៦- តាមដាន និងវាយតម្លៃការអនុវត្តខ្លឹមសារសហប្រតិបត្តិការអន្តរជាតិ ពាក់ព័ន្ធជាមួយវិស័យសាធារណការ និងដឹកជញ្ជូន ដែលមានចែងក្នុងកំណត់ហេតុ អនុស្សរណៈ ពិធីសារ និងកិច្ចព្រមព្រៀង ដែលបានចុះ ហត្ថលេខារួច ។

៧- បូកសរុបការងារសហប្រតិបត្តិការអន្តរជាតិជាមួយស្ថាប័ននានាតាមរបបកំណត់ ។

៨- ធ្វើរបាយការណ៍សកម្មភាពប្រចាំខែ ត្រីមាស ឆមាស ៩ ខែ និងឆ្នាំ ជូនថ្នាក់ដឹកនាំ ។

៩- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន ។

**មាត្រា៣.-**

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

វចនាសម្ព័ន្ធ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ត្រូវ កំណត់ដោយ ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

Chanthol

**ស៊ុន ចាន់ថុល**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:**...៥៣...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់

## អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

* * * * * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញ ព្រះរាជក្រឹត្យលេខ នស / រកត / ០២០១ / ០៣៦ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០១ ស្តីពីការបង្កើតក្រុមប្រឹក្សា-ជាតិកម្ពុជាដើម្បីស្ត្រី

-បានឃើញ ព្រះរាជក្រឹត្យលេខ នស / រកត / ០៨០៥ / ៣៨៨ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យ លេខ នស / រកត / ០២០១ / ០៣៦ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិ-កម្ពុជាដើម្បីស្ត្រី

-បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧

# សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ កំណត់ពីបេសកកម្ម មុខងារ ភារកិច្ច និងការរៀបចំរចនាសម្ព័ន្ធ របស់អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដែលហៅកាត់ថា (**ក.ជ.ក.ស.**) ។

## ជំពូកទី ២
## បេសកកម្ម តួនាទី និងភារកិច្ច

**មាត្រា ២.-**

អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ ជាអង្គភាពប្រតិបត្តិ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដែលត្រូវដឹកនាំ និងគ្រប់គ្រងដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរង មួយចំនួន តាមការចាំបាច់។

**មាត្រា ៣.-**

អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី មានបេសកកម្មអនុវត្តភារកិច្ចតាមការសម្រេចរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ។

ក្នុងបេសកកម្មនេះ អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ ជាសេនាធិការរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី (**ក.ជ.ក.ស.**) មានភារកិច្ចដូចតទៅ ÷

-លើកផែនការសកម្មភាពការងាររយៈពេលខ្លី មធ្យម វែង របស់ **ក.ជ.ក.ស.**

-សម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំរបាយការណ៍ជាតិ ស្តីពីការអនុវត្តអនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងប្រឆាំងនឹងនារីភេទ ស៊ី-ដ (CEDAW) ជូន **ក.ជ.ក.ស.** ដើម្បីពិនិត្យ និងកែលម្អដាក់ជូនរាជរដ្ឋាភិបាលសម្រេច ហើយផ្ញើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ

-ពិនិត្យតាមដានស្ថានភាពរបស់ស្ត្រី និងផ្តល់អនុសាសន៍ ដោយផ្អែកលើគោលនយោបាយជាតិ របស់រាជរដ្ឋាភិបាល និងគោលដៅសិទ្ធិស្ត្រីពិភពលោក

-ជម្រុញការផ្សព្វផ្សាយខ្លឹមសារអនុសញ្ញា ស៊ី-ដ ឱ្យបានទូលំទូលាយដល់មូលដ្ឋាន

-សិក្សាស្រាវជ្រាវច្បាប់ជាតិ-អន្តរជាតិ បទបញ្ជា វិធានការទាំងឡាយណា ដែលពាក់ព័ន្ធនឹងស្ត្រី ដើម្បីតាមដានវាយតម្លៃ និងលើកអនុសាសន៍

-ធ្វើសហប្រតិបត្តិការ និងសហការសម្របសម្រួលជាមួយក្រសួង ស្ថាប័ននានា អង្គការជាតិ អន្តរជាតិ និង

សង្គមស៊ីវិល ដើម្បីលើកអនុសាសន៍ជូន **គ.ជ.ក.ស.** ពិនិត្យ សម្រេច និងផ្ញើជូនរាជរដ្ឋាភិបាល

-ធានានិរន្តរភាព នៃដំណើរការរដ្ឋបាល របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

-គ្រប់គ្រងមន្ត្រី បុគ្គលិកនៃអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃ **គ.ជ.ក.ស.**

-គ្រប់គ្រងថវិកា និងសារពើភ័ណ្ឌរបស់អគ្គលេខាធិការដ្ឋាន ដោយអនុលោមតាមការសម្រេចរបស់ **គ.ជ.ក.ស.**

-រៀបចំកិច្ចប្រជុំសាមញ្ញ វិសាមញ្ញ និងបូកសរុបរាយការណ៍ប្រចាំឆ្នាំ រួមមានការធ្វើកំណត់ហេតុ និងរបាយការណ៍ អំពីសកម្មភាព និងលទ្ធផលការងាររបស់ **គ.ជ.ក.ស.**

-ចងក្រងព័ត៌មាន និងឯកសារទាំងអស់ ដែលពាក់ព័ន្ធទៅនឹងស្ត្រី ។

**មាត្រា ៤.-**

ថវិការបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី រួមមាន :

១-ថវិការដ្ឋ ជាឧបសម្ព័ន្ធនៃថវិកា របស់ក្រសួងកិច្ចការនារី ដែលមានកញ្ចប់ថវិកាដោយឡែករបស់ខ្លួន និងត្រូវស្ថិតនៅក្រោមច្បាប់ ស្តីពីហិរញ្ញវត្ថុ ។ អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ **គ.ជ.ក.ស.** ត្រូវលើកគម្រោង និងការពារ កញ្ចប់ថវិកាប្រចាំឆ្នាំ ផ្អែកទៅតាមសកម្មភាពការងាររបស់ខ្លួន ។

២- ជំនួយឧបត្ថម្ភពី អង្គការអន្តរជាតិ ប្រទេសផ្តល់អំណោយ សប្បុរសជនជាតិ និងអន្តរជាតិ ។

ប្រភពចំណូលទាំងអស់ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្រៅពីថវិការដ្ឋ ត្រូវបញ្ចូលក្នុងគណនីរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី នៅក្នុងធនាគារ ដែលអនុម័តដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី មាន រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី ជាអាណាប័ក និងអគ្គលេខាធិការ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ជាអាណាប័កផ្ទេរសិទ្ធិ ។ ការប្រើប្រាស់ថវិកាក្រៅពីភារកិច្ចដំណើរការប្រចាំថ្ងៃ ត្រូវមានការអនុញ្ញាត ពីក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ។

**មាត្រា ៥.-**

អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី មានសិទ្ធិប្រើប្រាស់ ត្រា របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ។

**មាត្រា ៦.-**

អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី មានភារកិច្ចលើកសំណើ ស្តីពីការតែងតាំង ផ្ទេរភារកិច្ច ការបញ្ឈប់ពីតំណែងនូវមន្ត្រីថ្នាក់ក្រោម ការជ្រើសរើសមន្ត្រីរាជការដែលមានក្របខ័ណ្ឌស្រាប់ និងបុគ្គលិកជាប់កិច្ចសន្យាជូនប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ពិនិត្យ និងសម្រេច តាមការចាំបាច់ ។

# ជំពូកទី ៣
# រចនាសម្ព័ន្ធ

**មាត្រា ៧.-**

អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ចែកចេញជាបីផ្នែក តាមរចនាសម្ព័ន្ធដូចតទៅ :

-ផ្នែក រដ្ឋបាល និងហិរញ្ញវត្ថុ

-ផ្នែក ផែនការ និងសហប្រតិបត្តិការ

-ផ្នែក នីតិកម្ម

អង្គការលេខរបស់អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៨.-**

ផ្នែក ត្រូវបែងចែកជាក្រុមកិច្ចការ ។ ផ្នែកនីមួយៗ ត្រូវបែងចែកយ៉ាងតិច បី ក្រុមកិច្ចការ ។

ការបែងចែកទទួលខុសត្រូវលើក្រុមកិច្ចការនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់ប្រធាន នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី តាមសំណើរបស់អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ ។

**មាត្រា ៩.-**

ផ្នែកនីមួយៗត្រូវដឹកនាំ គ្រប់គ្រងដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់។ ការកំណត់អំពីឋានៈរបស់ ផ្នែក និងក្រុមកិច្ចការ រួមមាន :

- ប្រធានផ្នែក មានឋានៈស្មើប្រធាននាយកដ្ឋាន
- អនុប្រធានផ្នែក មានឋានៈស្មើអនុប្រធាននាយកដ្ឋាន
- ប្រធានក្រុមកិច្ចការ មានឋានៈស្មើប្រធានការិយាល័យ
- អនុប្រធានក្រុមកិច្ចការ មានឋានៈស្មើអនុប្រធានការិយាល័យ

**មាត្រា ១០.-**

អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ អាចលើកសំណើជូនប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដើម្បីពិនិត្យ និងសម្រេចលើការបង្កើតអនុគណៈកម្មការជំនាញផ្សេងៗទៀត តាមតម្រូវការចាំបាច់ ។

# ជំពូកទី ៤

## មុខងារ និងភារកិច្ច របស់ផ្នែកនីមួយៗ

**មាត្រា ១១._**

ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ មានភារកិច្ច ដូចតទៅ :

- គ្រប់គ្រងមន្ត្រីរាជការ របស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
- ចាត់ចែង និងគ្រប់គ្រងឯកសាររដ្ឋបាល របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
- រៀបចំ តាក់តែងលិខិតរដ្ឋបាលនានា ធ្វើកំណត់ហេតុរាល់អង្គប្រជុំសាមញ្ញ និងវិសាមញ្ញរបស់ **ក.ជ.ក.ស.**
- រៀបចំ និងសរុបរបាយការណ៍ លទ្ធផល និងសកម្មភាព របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ជាប្រចាំ និងធ្វើការបូកសរុបរបាយការណ៍ប្រចាំឆ្នាំ
- លើកគម្រោងស្នើសុំ ថវិកាជាតិ និងដៃគូអភិវឌ្ឍន៍ ប្រមូលផ្តុំតម្រូវការនានា និងតាមដានរំលឹកពីការប្រតិបត្តិ
- គ្រប់គ្រងអចលនវត្ថុ ចលនវត្ថុ និងបញ្ជីសារពើភណ្ឌ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
- ផ្គត់ផ្គង់សម្ភារៈបរិក្ខារដល់អគ្គលេខាធិការដ្ឋាន និងកិច្ចប្រជុំនានា ដែលទាក់ទងនឹង **ក.ជ.ក.ស.**
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ប្រគល់ជូន ។

**មាត្រា ១២._**

ផ្នែកផែនការ និងសហប្រតិបត្តិការ មានភារកិច្ច ដូចតទៅ :

- រៀបចំផែនការសកម្មភាព ការងាររយៈពេលខ្លី មធ្យម វែង របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
- ពិនិត្យ ប្រមូលទិន្នន័យ និងវិភាគ លើលទ្ធផលការងារទទួលបានពីគ្រប់លំដាប់ថ្នាក់
- គ្រប់គ្រងគេហទំព័រ ដកស្រង់ព័ត៌មានប្រចាំថ្ងៃ និងរាយការណ៍
- និពន្ធ ផលិត និងចងក្រងឯកសារ ផ្សព្វផ្សាយព័ត៌មាន ដោយសហការជាមួយគ្រប់ប្រព័ន្ធផ្សព្វផ្សាយ
- រៀបចំ ផលិត សៀវភៅរូបភាព ផ្ទាំងរូប ខ្សែភាពយន្ត ប័ណ្ណផ្ទត់ ដែលទាក់ទងសកម្មភាពការងារ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
- ទំនាក់ទំនង សម្របសម្រួល និងសហការការងារជាមួយក្រសួង ស្ថាប័ន និងសង្គមស៊ីវិល
- ចូលរួមប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល លើកិច្ចការរបស់ខ្លួន
- រៀបចំពិធីការ និងដំណើរការរាល់កិច្ចប្រជុំ និងជំនួបពិភាក្សាផ្សេងៗ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ប្រគល់ជូន ។

**មាត្រា ១៣.-**

ផ្នែកនីតិកម្ម មានភារកិច្ចដូចតទៅ :

- សិក្សាស្រាវជ្រាវ អំពី ច្បាប់ជាតិ បទបញ្ញា វិធានទាក់ទងនឹងស្ត្រី និងចូលរួមធ្វើវិសោធនកម្ម ជាមួយអន្តរក្រសួង សង្គមស៊ីវិល អង្គការជាតិ អន្តរជាតិ ដែលពាក់ព័ន្ធ។
- ចូលរួមប្រជុំ តាមដាន វាយតម្លៃ សម្របសម្រួល ផ្តល់អនុសាសន៍ ទៅលើរាល់ការជម្រុញអនុវត្តច្បាប់ជាតិ កិច្ចព្រមព្រៀង អនុស្សរណៈ បទបញ្ញា និងវិធានការទាក់ទងនឹងស្ត្រី
- ពិនិត្យ និងតាមដានវាយតម្លៃ ការអនុវត្តគោលនយោបាយជាតិ ពាក់ព័ន្ធនឹងការបញ្ជ្រាបយេនឌ័រ តាមគ្រប់លំដាប់ថ្នាក់ រួមមានថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់មូលដ្ឋាន ឃុំ សង្កាត់
- តាមដាន វាយតម្លៃ លើការអនុវត្តច្បាប់ជាតិ ដូចជា ច្បាប់ ស្តីពីការបង្ក្រាបអំពើពង្រត់ លក់ដូរមនុស្ស អំពើធ្វើអាជីវកម្មលើមនុស្ស តាមគ្រប់លំដាប់ថ្នាក់
- ចូលរួមផ្សព្វផ្សាយ និងតាមដាន វាយតម្លៃ លើការអនុវត្តច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ
- ប្រមូល និងចងក្រងព័ត៌មាន លើករណីអំពើហិង្សាលើស្ត្រី ដើម្បីរៀបចំសម្របសម្រួលមូលដ្ឋានស្ថិតិឱ្យបានសមស្របតាមបច្ចុប្បន្នភាព
- សិក្សាស្រាវជ្រាវ ច្បាប់ អនុសញ្ញា សិទ្ធិសញ្ញាអន្តរជាតិទាក់ទងនឹងស្ត្រី និងតាមដាន វាយតម្លៃ លើការអនុវត្តច្បាប់នៅកម្ពុជា
- សម្របសម្រួល និងសហការជាមួយ ក្រសួង ស្ថាប័ន សង្គមស៊ីវិលនានា ក្នុងការរៀបចំរបាយការណ៍ជាតិ ស្តីពីការអនុវត្តអនុសញ្ញា ស៊ី-ដ នៅកម្ពុជា តាមអនុសាសន៍របស់អង្គការសហប្រជាជាតិ
- ជម្រុញការផ្សព្វផ្សាយអនុសញ្ញា ស៊ី-ដ នៅគ្រប់លំដាប់ថ្នាក់ ដល់មូលដ្ឋាន ឃុំ សង្កាត់
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ប្រគល់ជូន ។

## ជំពូកទី ៥

## ភារកិច្ចរបស់ក្រសួង ស្ថាប័ន និង ខេត្ត ក្រុង

**មាត្រា ១៤.-**

១-ក្រុមការងារបច្ចេកទេសយេនឌ័រនៃក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកបន្ថែមកិច្ចការរបស់ **គ.ជ.ក.ស.** សំដៅលើកកម្ពស់សមត្ថភាពចូលរួម ក្នុងភារកិច្ចទទួលខុសត្រូវតាមជំនាញនីមួយៗ ក្នុងក្រសួង ស្ថាប័នរបស់ខ្លួន ដើម្បីសរសេររបាយការណ៍ជាតិ ស្តីពីការអនុវត្តអនុសញ្ញា ស៊ី-ដ និងការផ្សព្វផ្សាយ ព្រមទាំងការសហការចុះតាមដាន វាយតម្លៃ ការអនុវត្តគោល

នយោបាយជាតិ និងច្បាប់ជាតិជាមួយ **គ.ជ.ក.ស.** ដើម្បីអនុវត្តផែនការសកម្មភាពការងារ របស់ **គ.ជ.ក.ស.** នៅតាមខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ រៀងៗខ្លួន។

២-មន្ទីរកិច្ចការនារីគ្រប់ខេត្ត ក្រុង និងជនបង្គោលយេនឌ័រ តាមមន្ទីរនានាជុំវិញខេត្ត ក្រុង ត្រូវទទួលបន្ទុកបន្ថែម កិច្ចការរបស់ **គ.ជ.ក.ស.** ។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**មាត្រា ១៥.-**

អនុក្រឹត្យលេខ ១១០ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្ត អនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ..៥៧......អនក្រ.បក ចុះថ្ងៃទី០៥...ខែ.មិថុនា...ឆ្នាំ ២០០៧

**ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃ គ.ជ.ក.ស.**

## អង្គការលេខ

## របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី



ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ..៥៧.....អនក្រ.បក ចុះថ្ងៃទី.០៧....ខែ.មិថុនា....ឆ្នាំ ២០០៧

**ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ ក.ជ.ក.ស.**

## អង្គការលេខ

## របស់អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី



## ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៤៣ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ អគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

| | | |
|---|---|---|
| ១- លោកវរសេនីយ៍ទោ | **ខាង សំផន** | អត្តលេខ ០៦៥០ |
| ២- លោកវរសេនីយ៍ទោ | **គឹម ខាសនា** | អត្តលេខ ០៦៧០ |
| ៣- លោកវរសេនីយ៍ទោ | **ចិន ចាន់** | អត្តលេខ ០១៣៦៥ |
| ៤- លោកស្រីវរសេនីយ៍ទោ | **សុខ ចន្ទីរ៉ា** | អត្តលេខ ០២២២៥ |
| ៥- លោកស្រីវរសេនីយ៍ទោ | **យក់ សុខា** | អត្តលេខ ០២២៥៧ |
| ៦- លោកវរសេនីយ៍ទោ | **សៀង យូជារ៉ង់** | អត្តលេខ ៥៤០៣៧ ។ |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០០៧*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល :*
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៤៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមុខតំណែង នាយនគរបាលជាតិ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស / រកម / ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៥០១ /១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១.-** ត្រូវបានសម្រួលមុខតំណែងលោកឧត្តមសេនីយ៍ត្រី **ខន្ធ សុមន្ត** អត្តលេខ ០៩៣៥ ពីអនុប្រធាននាយកដ្ឋានកណ្តាលមធ្យោបាយ ដើម្បីរងចាំទទួលការសំរេចតែងតាំងមុខតំណែងជាថ្មី ពីក្រសួងមហាផ្ទៃ ។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៤៥ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/ រកម ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/០៥០១ /១៧៨ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សំរេច

**មាត្រា ១ :** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ ***វរសេនីយ៍ឯក*** ជូនដល់នាយនគរបាលជាតិជាន់ខ្ពស់ នៃ ក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១-លោក វរសេនីយ៍ទោ **យាវ ម៉ាន់នី** អត្តលេខ ០៩៨៤
២-លោក វរសេនីយ៍ទោ **ឡឿន តិរម្យ** អត្តលេខ ៣៣០៥០
៣-លោក វរសេនីយ៍ទោ **ខៀវ ចាន់រ៉ា** អត្តលេខ ០៧៩៨ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ.ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៧*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល*
*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា ២*
*-ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៤៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងសមាសភាពអគ្គលេខាធិការរងបន្ថែម របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- យោងតាមសំណើរបស់ឯកឧត្តមប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងយោងតាមតម្រូវការចាំបាច់

### សម្រេច

**មាត្រា ១:** ត្រូវបានតែងតាំង លោក **អ៊ុន ចាន់ឡើ** បច្ចុប្បន្ន ប្រធាននាយកដ្ឋានត្រួតពិនិត្យ និងតាមដានគម្រោងវិនិយោគ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាអគ្គលេខាធិការរង នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី អគ្គលេខាធិការ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ:....៤៤៣..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

**ស ម្រេ ច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនលោកវរសេនីយ៍ឯក **ធើរិន អឹម តែឌលើ** ( Colonel Terence M. Tidler ) អនុព័ន្ធយោធាអាមេរិក ដែលមានស្នាដៃក្នុងការបំពេញភារកិច្ច នៅព្រះរាជាណាចក្រកម្ពុជា សំរេចបានលទ្ធផលល្អប្រសើរ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រី ក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៤៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៣៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ គណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនជប៉ុន ចំនួន០៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមចំណែកកសាងសាលាបឋមសិក្សា ចំនួន០២ខ្នង មាន១០បន្ទប់ បង្គន់អនាម័យ និងអណ្តូងទឹកសរុបថវិកា ចំនួន ៤៥.០០០ ដុល្លារអាមេរិក ស្ថិតនៅក្នុងខេត្តឧត្តរមានជ័យ និង ខេត្តសៀមរាប ដូចមានរាយនាមខាងក្រោម :-

១-លោក NAKAMURA HATSUHO កសាងសាលាបឋមសិក្សា ភូមិចារ ខេត្តឧត្តរមានជ័យ

២-លោក KOJIMA KENZO កសាងសាលាបឋមសិក្សា ឃុំ សែន សុខ ស្រុកក្រឡាញ់ ខេត្ត សៀមរាប

៣-លោក TSUNEJI NEGISHI ប្រធានអង្គការសមាគម ជំនួយកម្ពុជា សំរាប់សតវត្សទី ២១

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តឧត្តរមានជ័យ និងអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៧

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៤៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ នាយកខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី

**សម្រេច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០៣ រូប ដែលបានឧបត្ថម្ភថវិកាសំរាប់សាងសង់ អគារសិក្សាថ្មី ០១ខ្នង មាន០៥បន្ទប់ ជួសជុលអគារសិក្សា ចាស់០១ខ្នង មាន០៦បន្ទប់ និងសាងសង់បង្គន់អនាម័យ ០២បន្ទប់ នៅសាលាបឋមសិក្សា វាលម្លូ ស្ថិតក្នុងឃុំវាលម្លូ ស្រុកពញាក្រែក ខេត្តកំពង់ចាម ចំណាយអស់ទឹកប្រាក់ ចំនួន ៣៦.០០០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោម :-

១-លោក T.C.Swartz នាយកប្រតិបត្តិករទេសចរណ៍ នៅសហរដ្ឋអាមេរិក

២-លោកស្រីបណ្ឌិត Charlene Brannon នាយិកាប្រតិបត្តិករទេសចរណ៍ នៅសហរដ្ឋអាមេរិក

៣-កញ្ញា **រ៉ុត ចាន់តេនា** អនុប្រធានមូលនិធិអប្សរា

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៥០ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

ក្រោម

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿង ឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## សម្រេច

**មាត្រា១** : -ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនជនជាតិជប៉ុនចំនួន ០២ រូប ដែលបានយកអស់កំលាំងកាយចិត្ត ខិតខំប្រឹងប្រែងពុះពារគ្រប់ការលំបាក ដើម្បីបំពាក់នូវប្រព័ន្ធអគ្គីសនីប្រើដោយថាមពលព្រះអាទិត្យ និងខ្យល់ ចំនួន ០២ គ្រឿង នៅ មណ្ឌលសុខភាព ជ្រោយតាកែវ ឃុំជ្រោយតាកែវមួយកន្លែង និងមណ្ឌលសុខភាព ឈើខ្មៅ ឃុំឈើខ្មៅមួយកន្លែង ក្នុងស្រុកកោះធំ ខេត្តកណ្តាល ប្រកបដោយគុណភាព និងជាគុណប្រយោជន៍ដ៏ធំធេង ជួយដល់មណ្ឌលសុខភាពទាំងពីរខាងលើ ដូចមានរាយនាមខាងក្រោម :

១-លោក **មូតូហ៊ីរ៉ូ តាកាហាសឺ** *(MUTUHIRO TAKAHASHI)* ប្រធានក្រុមហ៊ុន កូស៊ីយ៉ូ តរប៉ូរ៉េសិន

២-លោក **ហ្គូ សូម៉ូត្ថា** *(GO SOMOTHA)* អ្នកសំរបសំរួលក្រុមហ៊ុន កូស៊ីយ៉ូ តរប៉ូរ៉េសិន

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសុខាភិបាលត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល** :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា ២
-រាជកិច្ច ✓
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៥៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

